# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០១...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១០១ អនក្រ.បក
## ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពី
## ការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា
## អាណត្តិទី៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល សមាសភាពសមាជិករាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសភាពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១២ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បកចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា អាណត្តិទី៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រាមួយ.-**

មាត្រា ១ នៃអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មកម្ពុជា ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា១.-ថ្មី**

ត្រូវបានទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិ សភាពាណិជ្ជកម្មកម្ពុជាចំនួន ៣៧រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | អ្នកឧកញ៉ា **គិត ម៉េង** | ជាប្រធានសភាពាណិជ្ជកម្មកម្ពុជា |
| ២. | ឧកញ៉ា **សុខ ហ៊ាង** | ជាអនុប្រធាន |
| ៣. | ឯកឧត្តមឧកញ៉ា **ហាក់ សុវណ្ណា** | ជាអនុប្រធាន |
| ៤. | ឧកញ៉ា **គួ ពុយ** | ជាអនុប្រធាន |
| ៥. | លោក **ហ៊ុយ ឡៀម** | ជាអនុប្រធាន |
| ៦. | ឧកញ៉ា **នុយ គី** | ជាអនុប្រធាន |
| ៧. | លោក **ឈុន ធំ** | ជាអនុប្រធាន |
| ៨. | ឧកញ៉ា **ហេង សំណាង** | ជាអនុប្រធាន |
| ៩. | លោក **ឡេង សុខគា** | ជាអនុប្រធាន |
| ១០. | ឧកញ៉ា **សុខ ស្រស់** | ជាអនុប្រធាន |
| ១១. | ឧកញ៉ា **ឡាយ ការ៉ង** | ជាអនុប្រធាន |
| ១២. | ឯកឧត្តម **លី អ៊ុនលី** | ជាអនុប្រធាន |
| ១៣. | លោក **ឈាង ខួន** | ជាអនុប្រធាន |
| ១៤. | លោក **កែម សុផារិទ្ធ** | ជាអនុប្រធាន |
| ១៥. | លោក **សំ ស៊ីថាយ** | ជាអនុប្រធាន |
| ១៦. | ឯកឧត្តមឧកញ៉ា **ស៊ីន សុខណា** | ជាអនុប្រធាន |
| ១៧. | ជំទាវឧកញ៉ា **កែម ម៉ាលី** | ជាអនុប្រធាន |
| ១៨. | ជំទាវឧកញ៉ា **លឹម ឈីវហូ** | ជាអនុប្រធាន |
| ១៩. | ឧកញ៉ា **ហាន់ ឃៀង** | ជាអនុប្រធាន |
| ២០. | ឯកឧត្តមឧកញ៉ា **ស៊ឹម ថៃ** | ជាអនុប្រធាន |
| ២១. | លោកស្រីឧកញ៉ា **ចាន់ សុផា** | ជាអនុប្រធាន |
| ២២. | ឧកញ៉ា **លឹម ហេង** | ជាអនុប្រធាន |
| ២៣. | ឯកឧត្តមឧកញ៉ា **ហ៊ី បាទី** | ជាអនុប្រធាន |
| ២៤. | ឧកញ៉ា **ឡៅ មេងហេង** | ជាអនុប្រធាន |
| ២៥. | ឧកញ៉ា **លី យុនថៃ** | ជាអនុប្រធាន |
| ២៦. | ឧកញ៉ា **លី ហួរ** | ជាអនុប្រធាន |
| ២៧. | ឧកញ៉ា **អាន ម៉ាឌី** | ជាអនុប្រធាន |

២៨. ឧកញ៉ា **ទិញ ហ៊ីរ** ជាអនុប្រធាន
១៩. ឧកញ៉ា **ឌី ពិសិដ្ឋ** ជាអនុប្រធាន
៣០. ឧកញ៉ា **គីម សាវុធ** ជាអនុប្រធាន
៣១. ឧកញ៉ា **ហុង ពីវ** ជាអនុប្រធាន
៣២. លោក **គុយ ម៉ាត** ជាអនុប្រធាន
៣៣. បណ្ឌិត **តាន់ មុន្នីវណ្ណា** ជាអនុប្រធាន
៣៤. ឧកញ៉ា **សុខ ពិសិដ្ឋ** ជាអនុប្រធាន
៣៥. លោក **គួច ឆេង** ជាអនុប្រធាន
៣៦. ឯកឧត្តមឧកញ៉ា **គិត ម៉េង** ជាហេរញ្ញិក
៣៧. ឧកញ៉ា **ណាង សុធី** ជាលេខាធិការ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ មករា ឆ្នាំ ២០១៧

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ដើម្បីចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com